**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន សាធារណជន មេត្តាជ្រាបថា កាលពីព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ នេះ ក្រសួងបានទទួលញត្តិរបស់តំណាងសហព័ន្ធសហជីព សមាគម អង្គការសង្គមស៊ីវិល និងសហគមន៍ ដែលធ្វើការក្នុងវិស័យការងារនិងសិទ្ធិមនុស្ស ដែលបានអំពាវនាវ ដល់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា ឱ្យយកចិត្តទុកដាក់ដោះស្រាយនូវវិធានការចំនួន ៧ចំណុច ដែលផ្តោតលើការត្រួតពិនិត្យវាយតម្លៃគម្រោងសាងសង់ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពកម្មករផ្នែកសំណង់ ការទូទាត់សំណងជូនជនរងគ្រោះនិងការផ្តន្ទាទោសជនដែលបង្កគ្រោះថ្នាក់ ការផ្អាកអ្នកម៉ៅការបន្តដែលគ្មានអាជ្ញាបណ្ណ ការធ្វើស្តូបរំលឹកការចងចាំព្រឹត្តិការណ៍ការបាក់រលំអគារ និងការអនុវត្តសេចក្តីណែនាំការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់។

ក្រសួងសូមបញ្ជាក់ថា ចំណុចដែលទាមទារមួយចំនួន ក្រសួងបាននឹងកំពុងអនុវត្តរួចហើយ។ ចំពោះមុខក្រសួងនឹងពិនិត្យដោះស្រាយយ៉ាងយកចិត្តទុកដាក់នូវរាល់សំណូមពរទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង។ ចំពោះរាល់សំណូមពរផ្សេងទៀតដែលផុតពីដែនសមត្ថកិច្ចរបស់ក្រសួង ក្រសួងនឹងបញ្ជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយបន្តទៀត។ ជាមួយគ្នានេះ ក្រសួងក៏បានត្រៀមខ្លួនជាស្រេចដើម្បីសហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីបន្តពិនិត្យនិងដោះស្រាយនូវរាល់កង្វល់នានាដែលបានលើកឡើង។

អាស្រ័យដូចជម្រាបជូនខាងលើ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១២រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩